

អង្គការគាំពារធនធានសមុទ្រ

ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ

(២០២៦-២០៣០)

អក្សរកាត់

CSR	Corporate Social Responsibility ការទទួលខុសត្រូវសង្គមរបស់សាជីវកម្ម
GBF	Global Biodiversity Framework ក្របខ័ណ្ឌជីវៈចម្រុះសកល
GEDSI	Gender Equality, Disability, and Social Inclusion សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម
PES	Payment for Ecosystem Services ការទូទាត់សម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី
M&E	Monitoring and Evaluation ការតាមដាន និងវាយតម្លៃ
MRPO	Marine Resource Protection Organisation អង្គការគាំពារធនធានសមុទ្រ
MPA	Marine Protected Area តំបន់ការពារសមុទ្រ
NbS	Nature-Based Solutions ដំណោះស្រាយផ្អែកលើធម្មជាតិ
OECMs	Effective Area-Based Conservation Measures វិធានការអភិរក្សតាមតំបន់ប្រកបដោយប្រសិទ្ធភាព
SO	Strategic Objective គោលបំណងយុទ្ធសាស្ត្រ

មាតិកា

អក្សរកាត់ 1
I. សេចក្តីផ្តើម 3
II. ចក្ខុវិស័យ បេសកកម្ម និងតម្លៃស្នូល 5
ចក្ខុវិស័យរបស់យើង 5
បេសកកម្មរបស់យើង 5
តម្លៃស្នូលរបស់យើង 6
គោលបំណងយុទ្ធសាស្ត្រ 7
ទ្រឹស្តីនៃការផ្លាស់ប្តូរ 7
III. ក្របខ័ណ្ឌគោលបំណងយុទ្ធសាស្ត្រ 8
គោលបំណងយុទ្ធសាស្ត្រ 8
គោលបំណងទី១៖ កសាងភាពជាដៃគូ និងអភិបាលកិច្ចល្អ 8
គោលបំណងទី២៖ ការគាំពារតំបន់ការពារសមុទ្រ 10
គោលបំណងទី៣៖ ហិរញ្ញប្បទានប្រកបដោយចីរភាព និងការបែងចែកផលប្រយោជន៍ 11
គោលបំណងទី៤៖ ការស្រាវជ្រាវ សមត្ថភាព និងនវានុវត្តន៍ 12
IV. យន្តការដំណោះស្រាយផ្អែកលើធម្មជាតិ 14
V. ក្របខ័ណ្ឌការតាមដាន និងការវាយតម្លៃ 16
VI. ក្របខ័ណ្ឌយុទ្ធសាស្ត្រភ្ជៀសគរមូលនិធិ 18

I. សេចក្តីផ្តើម

តំបន់ឆ្នេរ និងសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា គឺជាជម្រកនៃប្រព័ន្ធអេកូឡូស៊ីសមុទ្រដ៏សម្បូរបែប រួមមាន៖ ថ្មប៉ប្រះទឹក ស្មៅសមុទ្រ ព្រៃកោងកាង តំបន់ដីសើម ឆ្នេរខ្សាច់ និងកោះនានា។ ធនធានធម្មជាតិទាំងអស់នេះ មិនត្រឹមតែមានសារៈសំខាន់សម្រាប់ជីវៈចម្រុះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបម្រើជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់សហគមន៍ឆ្នេរផងដែរ។ បន្ថែមពីនេះ ធនធានទាំងនេះគាំទ្រដល់វិស័យជលផល និងវិស័យទេសចរណ៍ ព្រមទាំងផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់ៗ ដូចជាការពារតំបន់ឆ្នេរ និងការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ ។



ធនធានសមុទ្ររបស់កម្ពុជា ត្រូវបានកំណត់លក្ខណៈដោយវត្តមានព្រៃកោងកាងយ៉ាងច្រើន ជាពិសេសស្ថិតក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលជាជម្រកដ៏សំខាន់សម្រាប់ជីវិតសត្វសមុទ្រ ការពារឆ្នេរសមុទ្រ និងដើរតួជាកន្លែងផ្ទុកឧស្ម័នកាបូនិចយ៉ាងសំខាន់ ។ វត្តមានស្មៅសមុទ្រត្រូវបានរកឃើញនៅតាមបណ្តាខេត្តជាប់ឆ្នេរសមុទ្រ ជាពិសេសខេត្តកំពត និងខេត្តកែប ។ ធនធានទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រព័ន្ធអេកូឡូស៊ីសមុទ្រ ដោយផ្តល់ជាជម្រក និងជាប្រភពចំណីសម្រាប់ជីវៈចម្រុះសមុទ្រជាច្រើនប្រភេទ រួមមាន៖ ត្រី ផ្កាយសមុទ្រ អណ្តើកសមុទ្រ និងជាពិសេសសត្វជ្រូកទឹក ដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ ។ លើសពីនេះ ស្មៅសមុទ្រជួយបង្ការសំណឹកឆ្នេរ និងរក្សាគុណភាពទឹកឱ្យថ្លា ។ ថ្មប៉ប្រះទឹក ដែលសម្បូរជាងគេនៅជុំវិញប្រជុំកោះរ៉ុង កោះរ៉ុងសន្លឹម កោះស្តេច កោះតាំង កោះមូល កោះពូលូវ៉ែ និងកោះផ្សេងៗទៀត គាំទ្រដល់ជីវៈចម្រុះសមុទ្រដ៏សំបូរបែប រួមទាំងប្រភេទសត្វដែលកំពុងរងការគំរាមកំហែងដូចជាអណ្តើកសមុទ្រជាដើម ។ តំបន់ទាំងនេះក៏ជាគោលដៅពេញនិយមសម្រាប់វិស័យទេសចរណ៍សមុទ្រផងដែរ ។

វិស័យដលផល គឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ច និងសន្តិសុខស្បៀងរបស់ប្រទេសកម្ពុជា ដោយផ្តល់ជីវភាពរស់នៅដល់ប្រជាជនរាប់លាននាក់។ ទោះជាយ៉ាងនេះក្តី ការគំរាមកំហែងយ៉ាងខ្លាំងកំពុងកើតមានឡើង ខណៈដែលស្តុកត្រីមានការធ្លាក់ចុះ នេះក៏ដោយសារការអនុវត្តមិនប្រកបដោយចីរភាព ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារឱ្យមានវិធីសាស្ត្រដ៏ទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែលផែនការយុទ្ធសាស្ត្រនេះមានគោលបំណងផ្តល់ជូន។

ទោះបីជាមានសារៈសំខាន់យ៉ាងណាក៏ដោយ បរិស្ថានសមុទ្ររបស់កម្ពុជាកំពុងប្រឈមមុខនឹងការគំរាមកំហែងកាន់តែខ្លាំងឡើង។ ការនេសាទហួសកម្រិត ការបាត់បង់ទីជម្រក ការបំពុលសមុទ្រ និងផលប៉ះពាល់កាន់តែខ្លាំងឡើងនៃការប្រែប្រួលអាកាសធាតុ កំពុងដាក់សម្ពាធយ៉ាងខ្លាំងដល់ប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះទាំងនេះ។ ការធ្លាក់ចុះនៃសុខភាពធនធានសមុទ្រ ប៉ះពាល់ដោយផ្ទាល់ដល់ស្ថិរភាពសេដ្ឋកិច្ច និងសន្តិសុខស្បៀងរបស់សហគមន៍ឆ្នេរ បណ្តាលឱ្យភាពក្រីក្រ និងភាពងាយរងគ្រោះកាន់តែធ្ងន់ធ្ងរឡើង។

ដើម្បីឆ្លើយតបនឹងបញ្ហានេះ អង្គការគាំពារធនធានសមុទ្រ (MRPO) ត្រូវបានបង្កើតឡើងជាមួយនឹងចក្ខុវិស័យច្បាស់លាស់ ដើម្បីដោះស្រាយបញ្ហាប្រឈមបន្ទាន់ទាំងនេះ។ ការប្តេជ្ញាចិត្តរបស់យើង គឺធ្វើការសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹងការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងការអភិរក្សធនធានសមុទ្រ និងឆ្នេររបស់កម្ពុជា ដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ន និងទៅអនាគត។


II. ចក្ខុវិស័យ បេសកកម្ម និងតម្លៃស្នូល

ចក្ខុវិស័យរបស់យើង

ដើម្បីសម្រេចបាននូវអនាគតមួយដែលប្រព័ន្ធអេកូឡូស៊ីសមុទ្ររបស់កម្ពុជា មានចីរភាពជីវចម្រុះ សមុទ្រដ៏សម្បូរបែប និងភាពធន់ ដែលជាមូលដ្ឋានគ្រឹះសម្រាប់សហគមន៍ឆ្នេរដ៏រុងរឿង សម្រាប់វិបុលភាពជាតិ និងសេដ្ឋកិច្ចខៀវដ៏រស់រវើក។

បេសកកម្មរបស់យើង

ដើម្បីការពារ អភិរក្ស និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីសមុទ្ររបស់កម្ពុជា សម្រាប់សន្តិសុខ ស្បៀង កាលានុវត្តភាពសេដ្ឋកិច្ច សុខុមាលភាពសហគមន៍ និងនិរន្តរភាពបរិស្ថាន។ យើងសម្រេចកិច្ចការនេះ បានតាមរយៈការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ចំណេះដឹងមូលដ្ឋាន និងការអនុវត្តប្រកបដោយនវានុវត្តន៍។



តម្លៃស្នូលរបស់យើង

១. ឧទាឧភត្តន៍ (Innovation)៖ ទទួលយកបច្ចេកវិទ្យាថ្មីៗ និងវិធីសាស្ត្របន្សាំ ដើម្បីបង្កើតដំណោះស្រាយអភិរក្សដែលមានប្រសិទ្ធភាព និងអាចពង្រីកវិសាលភាពបាន។

២. ការគោរព (Respect)៖ ផ្តល់តម្លៃដល់សិទ្ធិអំណាច ចំណេះដឹង និងប្រពៃណីក្នុងតំបន់ ខណៈពេលដែលដើរតួជាអ្នកថែរក្សាបរិស្ថានសមុទ្រ។

៣. សុចរិតភាព (Integrity)៖ ប្រកាន់ខ្ជាប់នូវតម្លាភាព គណនេយ្យភាព និងស្តង់ដារសីលធម៌ខ្ពស់បំផុតក្នុងគ្រប់សកម្មភាព។

៤. បរិយាបន្ន (Inclusiveness)៖ ធានាឱ្យបាននូវសមធម៌ ភាពខុសប្លែក និងយុត្តិធម៌សង្គម ដោយបញ្ជ្រាបសម្លេងសហគមន៍ទាំងអស់ ទៅក្នុងដំណើរការសម្រេចចិត្ត។



គោលបំណងយុទ្ធសាស្ត្រ

១. បង្កើតនិងពង្រឹងភាពជាដៃគូជាមួយរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីការពារ អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រឡើងវិញ ដោយធានានូវសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ។

២. លើកកម្ពស់ការគ្រប់គ្រងតំបន់ការពារសមុទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីសមុទ្រសំខាន់ៗ។

៣. ធានានិងគ្រប់គ្រងយន្តការហិរញ្ញប្បទានប្រកបដោយចីរភាព រួមជាមួយការបែងចែកផលប្រយោជន៍ដោយតម្លាភាព ដើម្បីធានាបាននូវនិរន្តរភាពរយៈពេលវែងនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សសមុទ្រ។

៤. ពង្រឹងសមត្ថភាពបុគ្គលនិងស្ថាប័ន តាមរយៈការវិនិយោគលើការស្រាវជ្រាវដើម្បីជំរុញការគ្រប់គ្រងធនធានសមុទ្រឱ្យកាន់តែប្រសើរឡើង។



ទ្រឹស្តីនៃការផ្លាស់ប្តូរ

ប្រសិនបើ យើងធ្វើការវិនិយោគរួមគ្នាក្នុងការគ្រប់គ្រង ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រឡើងវិញ ព្រមទាំងកសាងសមត្ថភាពសហគមន៍មូលដ្ឋាន រួមផ្សំការអនុវត្តចំណេះដឹងបែបវិទ្យាសាស្ត្រ និងការលើកកម្ពស់សេដ្ឋកិច្ចខៀវប្រកបដោយនិរន្តរភាព នោះសុខភាពនៃប្រព័ន្ធអេកូឡូស៊ីសមុទ្រនឹងត្រូវបានកែលម្អ សហគមន៍នឹងទទួលបានចំណេះដំនាញ និងធនធានដែលត្រូវការ ហើយកាលានុវត្តភាពសេដ្ឋកិច្ចខៀវនឹងត្រូវបានបង្កើតឡើង និងបែងចែកដោយយុត្តិធម៌ ដែលជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងយូរអង្វែងសម្រាប់បរិស្ថានសមុទ្រ និងប្រជាជនកម្ពុជា។

III. ក្របខ័ណ្ឌគោលបំណងយុទ្ធសាស្ត្រ

ក្របខ័ណ្ឌគោលបំណងយុទ្ធសាស្ត្រ៖ពេល៥ឆ្នាំ របស់អង្គការ MRPO ត្រូវបានបង្កើតឡើងនៅលើក្របខ័ណ្ឌរួមបញ្ចូលគ្នា ដែលផ្សារភ្ជាប់ប្រព័ន្ធអេកូឡូស៊ីសមុទ្រ សុខុមាលភាពសង្គម ជីវភាពរស់នៅ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ វិធីសាស្ត្ររបស់យើងគឺពង្រឹងភាពធន់ទាំងនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធសង្គម-សេដ្ឋកិច្ច ដោយធានាថាកិច្ចខិតខំប្រឹងប្រែងអភិរក្ស និងការស្តារឡើងវិញនូវធនធានសមុទ្រ បង្កើតបានជាអត្ថប្រយោជន៍ជាក់ស្តែងសម្រាប់ធម្មជាតិ និងមនុស្ស។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីរួមចំណែកយ៉ាងសំខាន់ដល់សុខភាព និងនិរន្តរភាពរយៈពេលវែងនៃធនធានសមុទ្ររបស់កម្ពុជា ការពារសមត្ថភាពរបស់ធនធានទាំងនោះក្នុងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ គាំទ្រដល់ជីវៈចម្រុះដ៏សម្បូរបែប និងលើកកម្ពស់សុខុមាលភាព និងភាពធន់របស់សហគមន៍ឆ្នេរក្នុងការប្រឈមមុខនឹងបម្រែបម្រួលបរិស្ថាន។

គោលបំណងយុទ្ធសាស្ត្រ

គោលបំណងទី១៖ កសាងភាពជាដៃគូ និងអភិបាលកិច្ចល្អ

(SO1): បង្កើតកិច្ចសហការនិងពង្រឹងភាពជាដៃគូជាមួយរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីការពារ អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រឡើងវិញ ដោយធានានូវសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)

សកម្មភាពទី១	ការពិពណ៌នា
A1.1- ពង្រឹងកិច្ចសហការ និងការសម្របសម្រួលជាមួយយន្តការរបស់ភាគីពាក់ព័ន្ធដែលមានស្រាប់	ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរួមគ្នា អង្គការ MRPO នឹងធ្វើប្រតិបត្តិការងារដោយរួមបញ្ចូលរចនាសម្ព័ន្ធរដ្ឋាភិបាល និងអន្តរជាតិដែលបានបង្កើតឡើងស្រាប់ ដើម្បីជៀសវាងភាពស្ទួនគ្នា ពង្រឹងការអភិរក្សបច្ចុប្បន្ន និងរួមចំណែកដោយផ្តាល់ដល់គំនិតផ្តួចផ្តើមអនុវត្តច្បាប់ អោយស្របគ្នាជាមួយស្ថាប័នដៃគូ និងក្របខ័ណ្ឌដែលបានបង្កើតឡើងរួច។
A1.2- សហការជាមួយអ្នកជំនាញ ស្ថាប័នស្រាវជ្រាវ និងការផ្តល់អំណាចដល់អ្នកវិទ្យាសាស្ត្រពលរដ្ឋ	លើកកម្ពស់ការអភិរក្សសមុទ្រតាមរយៈការគ្រប់គ្រងផ្អែកលើវិទ្យាសាស្ត្រ និងនវានុវត្តន៍ ដោយទាញយកប្រយោជន៍ពីកិច្ចសហការស្រាវជ្រាវយុទ្ធសាស្ត្រ និងកម្មវិធីតាមដានគ្រប់ជ្រុងជ្រោយ។ សកម្មភាពទាំងនេះរួមមានការចាប់ដៃគូជាមួយស្ថាប័នសិក្សា និងអ្នកជំនាញ ដើម្បីកែលម្អគុណភាពទិន្នន័យ ការតាមដានប្រព័ន្ធអេកូឡូស៊ី និងការសម្រេចចិត្តផ្អែកលើកស្តង់។ បន្ថែមពីនេះ គំនិតផ្តួចផ្តើមនេះផ្តល់អំណាចដល់អ្នកវិទ្យាសាស្ត្រពលរដ្ឋ និងអ្នកជំនាញសមុទ្រជំនាន់ក្រោយ ឱ្យចូលរួមយ៉ាងសកម្មក្នុង

	កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ និងការស្តារឡើងវិញក្នុងក្របខ័ណ្ឌជាតិដែលបានបង្កើតឡើង។
A1.3- ពង្រឹងយន្តការ និងក្របខ័ណ្ឌសម្របសម្រួលដើម្បីការពារ អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រប្រកបដោយប្រសិទ្ធភាព	ពង្រឹងការពារ និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រឡើងវិញ តាមរយៈការបង្កើនអភិបាលកិច្ច ការសម្របសម្រួលឱ្យកាន់តែរលូន ការបង្កើតនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ការបង្កលក្ខណៈងាយស្រួលដល់កិច្ចសន្ទនា និងការអនុវត្តសកម្មភាពស្រមគ្នាជាមួយផែនការជាតិ ដើម្បីធានានូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាដែលមានលក្ខណៈបរិយាបន្ន តម្លាភាព និងផ្អែកលើលទ្ធផល។
A1.4- លើកកម្ពស់ការចូលរួម និងភាពជាម្ចាស់ការរបស់សហគមន៍	ដើម្បីជំរុញកិច្ចសហការ និងការផ្លាស់ប្តូរចំណេះដឹងតាមរយៈវេទិកាជំនាញ និងសិក្ខាសាលា។ ក្រុមការងារសហគមន៍គំរូផ្តល់អំណាចដល់ថ្នាក់ដឹកនាំមូលដ្ឋានជំរុញការដឹកនាំការអភិរក្ស ដោយមានការលើកកម្ពស់ស្ត្រី និងក្រុមងាយរងគ្រោះ សម្រាប់អភិបាលកិច្ចបរិយាបន្ន និងការគ្រប់គ្រងធនធានសមុទ្រប្រកបដោយសមធម៌។
A1.5- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនង និងការផ្សព្វផ្សាយ ដើម្បីការពារ អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ	អនុវត្តផែនការទំនាក់ទំនងប្រចាំឆ្នាំ ដែលរួមមានឧបករណ៍ផ្សព្វផ្សាយការយល់ដឹងស្របគ្នាទៅតាមព្រឹត្តិការណ៍បរិស្ថានក្នុងតំបន់ និងអន្តរជាតិ។ រៀបចំ និងបោះពុម្ពផ្សាយព័ត៌មានបែបវិទ្យាសាស្ត្រ ខិតប័ណ្ណ និងវីដេអូអប់រំ។ល។ ចូលរួមយ៉ាងសកម្មតាមរយៈប្រព័ន្ធផ្សព្វផ្សាយឌីជីថល សិក្ខាសាលាសិក្សា និងសន្និសីទសហគមន៍ឆ្នេរ ដើម្បីពង្រីកសារអភិរក្ស និងជំរុញការចូលរួមរបស់សាធារណជន។
A1.6- ជះឥទ្ធិពលលើការផ្លាស់ប្តូរឥរិយាបថសម្រាប់ប្រព័ន្ធអេកូឡូស៊ីសមុទ្រ	លើកកម្ពស់ការអនុវត្តក្នុងតំបន់ឆ្នេរប្រកបដោយនិរន្តរភាព ដោយស្របទៅតាមអត្ថប្រយោជន៍លើកទឹកចិត្តផ្នែកសង្គម និងសេដ្ឋកិច្ច ជាមួយនឹងការគ្រប់គ្រងបរិស្ថាន និងការអនុលោមតាមច្បាប់។ ជំរុញគណនេយ្យភាពរបស់សហគមន៍ និងវិស័យឯកជនតាមរយៈកម្មវិធីវិញ្ញាបនបត្រអេកូឡូស៊ីសម្រាប់ការកាត់បន្ថយកាកសំណល់ និងការផ្គត់ផ្គង់ដោយទទួលខុសត្រូវ ដោយប្រើប្រាស់ការផ្សព្វផ្សាយអោយចំគោលដៅ ដើម្បីបង្ហាញពីទំនាក់ទំនងដ៏សំខាន់រវាងសុខភាពប្រព័ន្ធអេកូឡូស៊ី និងស្ថិរភាពសង្គម-សេដ្ឋកិច្ច។
A1.7- បញ្ចូល GEDSI ក្នុងការរៀបចំ និងការអនុវត្តគម្រោង	បង្កើតគោលការណ៍ណែនាំគ្រប់ជ្រុងជ្រោយ ដើម្បីបញ្ចូល GEDSI នៅគ្រប់ដំណាក់កាលនៃគម្រោង ចាប់ពីការរៀបចំរហូតដល់ការវាយតម្លៃ។ រៀបចំការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ ដើម្បីធានាបាននូវការអនុវត្តជាក់ស្តែងក្នុងប្រតិបត្តិការប្រចាំថ្ងៃ។ ចូលរួមយ៉ាងសកម្មជាមួយស្ត្រី យុវជន ជនមានពិការភាព និងក្រុមងាយរងគ្រោះ ក្នុងដំណើរការសម្រេច

	ចិត្ត ដើម្បីជំរុញការគ្រប់គ្រងធនធានសមុទ្រប្រកបដោយបរិយាបន្ន និងសមធម៌។

គោលបំណងទី២៖ គាំពារតំបន់ការពារសមុទ្រ និងស្ដារឡើងវិញ

SO2: លើកកម្ពស់ការគ្រប់គ្រងតំបន់ការពារសមុទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងការស្ដារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីសមុទ្រសំខាន់ៗ។

សកម្មភាពទី២	ការពិពណ៌នា
A2.1- គាំទ្រដល់ការបង្កើត និងការពង្រឹងតំបន់ការពារសមុទ្រ (MPAs) និងវិធានការអភិរក្សផ្អែកលើតំបន់ប្រកបដោយប្រសិទ្ធភាព (OECMs)	ធ្វើការវាយតម្លៃទីតាំង ដើម្បីកំណត់អត្តសញ្ញាណទីជម្រកសំខាន់ៗ សម្រាប់ការការពារ និងការស្ដារឡើងវិញ។ ពង្រឹងសមត្ថភាពស្ថាប័នតាមរយៈការបណ្តុះបណ្តាលចំគោលដៅ និងការបែងចែកធនធាន។ រៀបចំផែនការគ្រប់គ្រងគ្រប់ជ្រុងជ្រោយដែលបញ្ចូល OECMs ជាមួយ MPAs ដើម្បីធានាបាននូវបណ្តាញអភិរក្សឆ្នេរដែលមានភាពស្អិតរមួត ភាពធន់ និងអភិបាលកិច្ចល្អ។
A2.2- គាំទ្រដល់ការធ្វើសមាហរណកម្មរចនាសម្ព័ន្ធគ្រប់គ្រងធនធានសហគមន៍ទំនើប	បង្កើតគណៈកម្មាធិការចម្រុះភាគីពាក់ព័ន្ធ ដើម្បីជំរុញអភិបាលកិច្ចបែបសហការ និងធានាឱ្យមានការសម្រេចចិត្តប្រកបដោយបរិយាបន្ន។ អនុវត្តយន្តការបែងចែកផលប្រយោជន៍ប្រកបដោយតម្លាភាព និងក្របខ័ណ្ឌគណនេយ្យភាពដ៏រឹងមាំ ដើម្បីធានាថាការលើកទឹកចិត្តដល់ការអភិរក្សត្រូវបានបែងចែកដោយសមធម៌ ហើយធនធានត្រូវបានគ្រប់គ្រងដោយទទួលខុសត្រូវក្នុងចំណោមអ្នកចូលរួមទាំងអស់។
A2.3- ដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាបន្សាំ និងរួមបញ្ចូលគ្នាសម្រាប់ឧបករណ៍គ្រប់គ្រងតំបន់ការពារសមុទ្រនិងសហគមន៍ឆ្នេរ	ប្រើប្រាស់បច្ចេកវិទ្យាអភិរក្សកម្រិតខ្ពស់ ដូចជាការអង្កេតពីចម្ងាយ (Remote Sensing) និងការប្រមូលទិន្នន័យជាក់ស្តែង (Real-time data collection) ដើម្បីកែលម្អការគ្រប់គ្រងតំបន់ការពារសមុទ្រ និងសហគមន៍ឆ្នេរ។ ដំណោះស្រាយបែបឌីជីថលទាំងនេះនឹងលើកកម្ពស់ការតាមដានប្រព័ន្ធអេកូឡូស៊ី ការរកឃើញសកម្មភាពមនុស្ស ការរាយការណ៍របស់សហគមន៍ និងអភិបាលកិច្ចសមុទ្រផ្អែកលើទិន្នន័យជាក់លាក់។
A2.4- អនុញ្ញាតឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃរួមគ្នា	សហការជាមួយសហគមន៍ អាជ្ញាធរ និងភាគីពាក់ព័ន្ធ ដើម្បីកំណត់សូចនាករប្រតិបត្តិការ និងលទ្ធផល សម្រាប់វាស់វែងប្រសិទ្ធភាពនៃតំបន់ការពារសមុទ្រ។

គោលបំណងទី៣៖ ហិរញ្ញប្បទានប្រកបដោយចីរភាព និងការបែងចែកផលប្រយោជន៍

SO3: ជានា និងគ្រប់គ្រងយន្តការហិរញ្ញប្បទានប្រកបដោយចីរភាព រួមជាមួយការបែងចែកផលប្រយោជន៍ដោយតម្លាភាព ដើម្បីជានាបាននូវនិរន្តរភាពរយៈពេលវែងនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សសមុទ្រ

សកម្មភាពទី៣	ការពិពណ៌នា
A3.1- ស្រាវជ្រាវ និងរៀបចំស្តង់ដារសម្រាប់វិស័យទេសចរណ៍ធម្មជាតិសមុទ្រ	ធ្វើការសិក្សាស៊ីជម្រៅអំពីការអនុវត្តល្អៗជាសកលសម្រាប់សកម្មភាពមុជទឹក (diving and snorkeling) ប្រកបដោយនិរន្តរភាព ដើម្បីកំណត់អត្តសញ្ញាណគំរូទេសចរណ៍ផ្អែកលើការអភិរក្សដែលទទួលបានជោគជ័យ។ ប្រើប្រាស់ការយល់ដឹងទាំងអស់នេះ ដើម្បីសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំគោលការណ៍ណែនាំជាតិ និងស្តង់ដារប្រតិបត្តិសម្រាប់ប្រតិបត្តិករទេសចរណ៍នៅកម្ពុជា។
A3.2- លើកកម្ពស់គំរូសហគមន៍ទេសចរណ៍ធម្មជាតិ (CBET) នៃប្រព័ន្ធអេកូឡូស៊ីសមុទ្រប្រកបដោយនិរន្តរភាព	រៀបចំការផ្តល់ជូនកញ្ចប់សេវាកម្មទេសចរណ៍ ដោយរួមបញ្ចូលសកម្មភាពកម្សាន្តនានា ជាមួយនឹងការអភិរក្សជាក់ស្តែង និងទទួលបានបទពិសោធន៍សិក្សាផ្ទាល់។ ធ្វើការចាប់ដៃគូជាមួយប្រតិបត្តិករ និងអាជ្ញាធរ ជំរុញគំរូសហគមន៍អេកូទេសចរណ៍ (CBET) ដែលបង្កើតជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងផ្តល់ការលើកទឹកចិត្តដល់ការការពារទីជម្រកសមុទ្រ ដើម្បីជានាបាននូវការគ្រប់គ្រងបរិស្ថានរយៈពេលវែង និងវិបុលភាពក្នុងតំបន់។
A3.3- លើកកម្ពស់ជម្រកកាបូនខៀវ	ផ្តួចផ្តើមគំនិតជម្រក "កាបូនខៀវ" តាមរយៈការស្តារព្រៃកោងកាង និងស្មៅសមុទ្រ ដើម្បីស្រូបយកកាបូន។ ធ្វើការវាយតម្លៃក្នុងស្រុកដើម្បីវាស់វែងការផ្ទុកកាបូន និងរៀបចំគម្រោងឥណទានកាបូនដែលបង្កើតមូលនិធិប្រកបដោយនិរន្តរភាព។ បង្វែរចំណូលទាំងនេះទៅក្នុងកិច្ចការពារធ្នេរសមុទ្រដឹកនាំដោយសហគមន៍ ដែលផ្តល់នូវប្រភពដែលអាចទុកចិត្តបានសម្រាប់ការស្តារឡើងវិញ និងការគ្រប់គ្រងបរិស្ថានជាបន្តបន្ទាប់។
A3.4- អភិវឌ្ឍសហគ្រាសសហគមន៍ធ្នេរទំនើប និងលទ្ធភាពទទួលបានទីផ្សារ	វាយតម្លៃសហគមន៍ដើម្បីកំណត់អត្តសញ្ញាណតម្រូវការសង្គម-សេដ្ឋកិច្ច។ គាំទ្រដល់ការអភិវឌ្ឍផលិតផលក្នុងស្រុកតាមរយៈការកែលម្អគុណភាព និងធានាលទ្ធភាពទទួលបានទីផ្សារ ដោយផ្សារភ្ជាប់សហគ្រាសសហគមន៍ទៅនឹងខ្សែច្រវាក់តម្លៃប្រកបដោយនិរន្តរភាព ដើម្បីធ្វើឱ្យប្រភពចំណូលគ្រួសារនៅតាមតំបន់ធ្នេរមានភាពចម្រុះ។
A3.5- គំរូហិរញ្ញប្បទានប្រកបដោយនិរន្តរភាព៖ យន្តការទីផ្សារ និងមិនមែនទី	អនុវត្តគំរូហិរញ្ញប្បទានប្រកបដោយនិរន្តរភាព សម្រាប់មូលនិធិអភិរក្សរយៈពេលវែង និងបង្កើតក្របខ័ណ្ឌបែងចែកផលប្រយោជន៍ប្រកបដោយតម្លាភាព ដើម្បីជានាបាននូវការបែងចែកចំណូលប្រកបដោយ

ផ្សារ និងការបែងចែកផលប្រយោជន៍	សមធម៌ និងជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងស្រុកក្នុងការការពារបរិស្ថាន។
A3.6- ពង្រឹងយន្តការការពារសុវត្ថិភាពសង្គម និងបរិស្ថាន	ធ្វើការវាយតម្លៃផលប៉ះពាល់សង្គមដើម្បីកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងគម្រោងជាមុន។ បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាប្រកបដោយតម្លាភាព និងងាយស្រួលសម្រាប់សមាជិកសហគមន៍ ដើម្បីរាយការណ៍អំពីកង្វល់ដោយសុវត្ថិភាពនិងដោះស្រាយវិវាទដោយយុត្តិធម៌ពេញមួយដំណើរការនៃគម្រោង។

គោលបំណងទី៤៖ ស្រាវជ្រាវ សមត្ថភាព និងឆន្ទានុភាព

SO4: ពង្រឹងសមត្ថភាពបុគ្គល និងស្ថាប័ន តាមរយៈការវិនិយោគលើការស្រាវជ្រាវ ដើម្បីជំរុញការគ្រប់គ្រងធនធានសមុទ្រឱ្យកាន់តែប្រសើរឡើង។

សកម្មភាពទី៤	ការពិពណ៌នា
A4.1- ពង្រឹងសមត្ថភាពជាតិ និងមូលដ្ឋានលើការគ្រប់គ្រងបន្សុំនៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ	លើកកម្ពស់សមត្ថភាពគ្រប់គ្រងបន្សុំនៃប្រព័ន្ធអេកូឡូស៊ីសមុទ្រក្នុងកម្រិតជាតិ និងមូលដ្ឋាន តាមរយៈការវាយតម្លៃចន្លោះខ្វះខាតចំគោលដៅក្នុងវិទ្យាសាស្ត្រសមុទ្រ និងការគ្រប់គ្រងទិន្នន័យ បន្ទាប់មកដោយការបណ្តុះបណ្តាលឯកទេស សិក្ខាសាលាបច្ចេកទេស និងកម្មវិធីផ្តល់ប្រឹក្សា លើបច្ចេកទេសការពារ និងការស្តារឡើងវិញ។
A4.2- លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការតាមដានប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងដំណោះស្រាយវិស្វកម្ម	ជំរុញការស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងការតាមដានប្រព័ន្ធអេកូឡូស៊ី និងវិស្វកម្មសមុទ្រ ដោយបង្កើតវិធីសាស្ត្រ ប្រមូលទិន្នន័យតាមស្តង់ដារ ធ្វើការវាយតម្លៃជាទៀងទាត់លើសុខភាពថ្មប៉ប្រះទឹក និងស្មៅសមុទ្រ ខណៈពេលដែលប្រើប្រាស់វិស្វកម្មអេកូឡូស៊ីដើម្បីគាំទ្រដល់ការស្តារទីជម្រកបកប្រែលទ្ធផលស្រាវជ្រាវទៅជាផែនការគ្រប់គ្រងដែលអាចអនុវត្តបាន ដើម្បីធានាបាននូវភាពធន់រយៈពេលវែងនៃជីវៈចម្រុះសមុទ្រ។
A4.3- ជំរុញ និងការបន្សាំ នវានុវត្តន៍ និងបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសមុទ្រ	ទទួលយក និងពង្រីកវិសាលភាពបច្ចេកវិទ្យានវានុវត្តន៍ និងឧបករណ៍ឌីជីថល ដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសមុទ្រ។ ដាក់ពង្រាយប្រព័ន្ធតាមដានកម្រិតខ្ពស់ ដើម្បីតាមដានសុខភាពទីជម្រក និងការប្រើប្រាស់ធនធានកែលម្អដំណោះស្រាយបច្ចេកទេសទាំងនេះជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន ដោយធានាថាយុទ្ធសាស្ត្រគ្រប់គ្រងនៅតែមានភាពឆ្លើយតបទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌបរិស្ថាន។
A4.4- ផ្តល់អំណាចដល់អ្នកជំនាញវ័យក្មេងក្នុងតំបន់	បង្កើតវេទិកាសិក្សា ដើម្បីផ្តល់អំណាចដល់អ្នកជំនាញវ័យក្មេងក្នុងតំបន់ក្នុងវិស័យគាំពារធនធានសមុទ្រ ផ្តល់លទ្ធភាពទទួលបានគំរូបណ្តុះ

តាមរយៈវេទិកាសិក្សាអំពីការគាំពារធនធានសមុទ្រ	បណ្តាលឯកទេស ធនធានបច្ចេកទេស និងឧបករណ៍ សហការដែលជំរុញការអភិវឌ្ឍជំនាញ។ តាមរយៈការផ្សារភ្ជាប់គម្លាតរវាងចំណេះដឹងសិក្សា និងការអនុវត្តជាក់ស្តែង វេទិកានេះគាំទ្រដល់អ្នកដឹកនាំអភិរក្សជំនាន់ក្រោយក្នុងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសមុទ្រ ប្រកបដោយប្រសិទ្ធភាព។

IV. យន្តការដំណោះស្រាយផ្អែកលើធម្មជាតិ

អង្គការ MRPO នឹងអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ (NbS) ដើម្បីដោះស្រាយបញ្ហាប្រឈមផ្អែកបរិស្ថាន និងសង្គមក្នុងបរិបទសមុទ្រ។ NbS គឺជាសកម្មភាពដែលការពារ គ្រប់គ្រងប្រកបដោយចីរភាព និងស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិឡើងវិញ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងសង្គមប្រកបដោយប្រសិទ្ធភាព ដោយផ្តល់អត្ថប្រយោជន៍ដល់មនុស្ស និងជីវៈចម្រុះ។

គោលបំណងយុទ្ធសាស្ត្រ (SO)	ការផ្តោតសំខាន់លើ NbS	សកម្មភាព NbS សង្ខេប (Concise NbS Action)	ការអនុវត្តស្រប (Alignment)
SO1: ភាពជាដៃគូ និងអភិបាលកិច្ចល្អ	ការគ្រប់គ្រងបែបសហការ និងបរិយាបន្ន	ពង្រឹងអភិបាលកិច្ចសមុទ្រតាមរយៈពិធីការអន្តរស្ថាប័ន ភាពជាដៃគូស្រាវជ្រាវ និងក្រុមការងារសហគមន៍។ ជានានូវការសម្របសម្រួលប្រកបដោយតម្លាភាព និងការសម្រេចចិត្តផ្អែកលើវិទ្យាសាស្ត្រ ដោយប្រើប្រាស់ក្របខ័ណ្ឌ GEDSI និងយុទ្ធសាស្ត្រផ្លាស់ប្តូរឥរិយាបថ ដោយចូលរួមយ៉ាងសកម្ម ជាមួយវិស័យឯកជន និងក្រុមងាយរងគ្រោះក្នុងការស្តារតំបន់ឆ្នេរឡើងវិញ។	អន្តរវិស័យ និងបរិយាបន្ន
SO2: ការគ្រប់គ្រងតំបន់ការពារសមុទ្រ និងការស្តារឡើងវិញ	ភាពធន់នៃតំបន់ឆ្នេរផ្អែកលើប្រព័ន្ធអេកូឡូស៊ី	ពង្រឹងបណ្តាញ MPA និង OECM តាមរយៈការវាយតម្លៃទីជម្រក និងការគ្រប់គ្រងផ្អែកលើទិន្នន័យ។ ដាក់ពង្រាយបច្ចេកវិទ្យាតាមដាន និងប្រព័ន្ធ M&E រួមគ្នា ដើម្បីតាមដានសុខភាពប្រព័ន្ធអេកូឡូស៊ី ខណៈពេលដែលបង្កើតរចនាសម្ព័ន្ធសហគមន៍សហការ សម្រាប់ការគ្រប់គ្រងធនធានប្រកបដោយបរិយាបន្ន និងសមធម៌។	អាចអនុវត្តបាន និងដាក់ស្តែង
SO3: ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព និងការបែងចែកផលប្រយោជន៍	សេដ្ឋកិច្ចខៀវ ចម្រុះ និងហិរញ្ញវត្ថុប្រកបដោយសមធម៌	បង្កើតលំហូរមូលនិធិចម្រុះតាមរយៈការរៀបចំស្តង់ដារអេកូទេសចរណ៍ គម្រោងឥណទានកាបូនខៀវ និងសហគ្រាសសហគមន៍ប្រកបដោយនិរន្តរភាព។ ដាក់ឱ្យដំណើរការនូវយន្តការបែងចែកផលប្រយោជន៍ និងការការពារសុវត្ថិភាព	និរន្តរភាព និងដាក់ស្តែង

		ដោយតម្លាភាព ដើម្បីធានាថាចំណូលត្រូវបានបែងចែកដោយសមធម៌ ដោយផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុរយៈពេលវែងដល់ ភាគីពាក់ព័ន្ធក្នុងស្រុក ដើម្បីការពារនិងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ។	
SO4: ការស្រាវជ្រាវ សមត្ថភាព និងនវានុវត្តន៍	**ការគ្រប់គ្រងបន្សាំផ្អែកលើវិទ្យាសាស្ត្រ និងការផ្តល់អំណាចដល់អ្នកជំនាញ**	ពង្រឹងសមត្ថភាពស្ថាប័ន និងមូលដ្ឋានដោយបញ្ជាបការស្រាវជ្រាវសមុទ្រកម្រិតខ្ពស់ វិស្វកម្មអេកូឡូស៊ី និងឧបករណ៍តាមដានឌីជីថល ទៅក្នុងក្របខ័ណ្ឌគ្រប់គ្រងបន្សាំ។ បង្កើតវេទិកាសិក្សា និងកម្មវិធីអភិវឌ្ឍន៍ជំនាញ ដើម្បីផ្តល់អំណាចដល់អ្នកអភិរក្សជំនាន់ក្រោយ ជាមួយនឹងជំនាញបច្ចេកទេសដែលចាំបាច់ ដើម្បីតាមដាន និងការពារជីវៈចម្រុះសមុទ្រ។	**ការស្រាវជ្រាវ និងការបន្សាំ**

V. ក្របខ័ណ្ឌការតាមដាន និងការវាយតម្លៃ

អង្គការ MRPO នឹងអនុវត្តក្របខ័ណ្ឌការតាមដាន និងការវាយតម្លៃ (M&E) ដ៏រឹងមាំមួយ ដើម្បីធានាថាគោលបំណងយុទ្ធសាស្ត្រទាំងអស់ត្រូវបានសម្រេចដោយតម្លាភាព ហើយសកម្មភាពអភិរក្សនាំទៅរកផលប៉ះពាល់ដែលអាចវាស់វែងបាន។ ប្រព័ន្ធនេះត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឱ្យមានការគ្រប់គ្រងបែបបន្សាំ ដែលជួយឱ្យអង្គការអាចកែលម្អយុទ្ធសាស្ត្ររបស់ខ្លួនផ្អែកលើទិន្នន័យជាក់ស្តែង និងបម្រែបម្រួលបរិស្ថាន។

៥.១ សូចនាករ និងក្របខ័ណ្ឌ

ដើម្បីវាស់វែងប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រឆ្នាំ ២០២៦-២០៣០ អង្គការ MRPO នឹងប្រើប្រាស់ប្រព័ន្ធសូចនាករពីរថ្នាក់ ៖

- **សូចនាករប្រតិបត្តិការ** (Operational Indicators): តាមដានការបញ្ចប់សកម្មភាពជាក់លាក់ ដូចជាចំនួនសិក្ខាសាលា GEDSI ដែលបានរៀបចំ ឬទំហំផ្ទៃដីព្រៃកោងកាងដែលបានស្តារឡើងវិញ។
- **សូចនាករលទ្ធផល** (Outcome Indicators): វាស់វែងសុខភាព និងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី ដូចជាការកើនឡើងនៃជីវម៉ាសត្រី ដង់ស៊ីតេស្មៅសមុទ្រ និងស្ថិរភាពសេដ្ឋកិច្ចនៃគ្រួសារប្រជាជនរស់នៅតាមតំបន់ឆ្នេរ។

៥.២ យន្តការតាមដានរួមគ្នា

ស្របតាមគោលបំណងយុទ្ធសាស្ត្រទី ២ អង្គការ MRPO នឹងបង្កើតប្រព័ន្ធ M&E រួមគ្នា ៖

ការចូលរួមរបស់ភាគីពាក់ព័ន្ធ (Stakeholder Engagement)៖ សហការជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ ដើម្បីកំណត់រង្វាស់នៃភាពជោគជ័យ។

បច្ចេកវិទ្យាកម្រិតខ្ពស់ (Advanced Technology)៖ ប្រើប្រាស់ការអង្កេតពីចម្ងាយ និងការប្រមូលទិន្នន័យឌីជីថលជាក់ស្តែង ដើម្បីតាមដានសុខភាពទីជម្រក និងសកម្មភាពមនុស្សនៅក្នុងតំបន់ការពារសមុទ្រ (MPAs)។

វិទ្យាសាស្ត្រពលរដ្ឋ (Citizen Science)៖ ផ្តល់អំណាចដល់ "អ្នកវិទ្យាសាស្ត្រពលរដ្ឋ" ក្នុងតំបន់ និងអ្នកជំនាញវ័យក្មេង ឱ្យចូលរួមក្នុងការប្រមូលទិន្នន័យ ដោយផ្សារភ្ជាប់គម្លាតរវាងការស្រាវជ្រាវវិទ្យាសាស្ត្រ និងចំណេះដឹងមូលដ្ឋាន។

៥.៣ ការរាយការណ៍ និងការសិក្សា

ការត្រួតពិនិត្យប្រចាំឆ្នាំ (Annual Reviews)៖ វឌ្ឍនភាពនឹងត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំ ធៀបនឹងផែនការ ៥ ឆ្នាំ ដើម្បីធានាបាននូវការអនុវត្តស្របគ្នាទៅនឹងគោលដៅបរិស្ថានថ្នាក់ជាតិ។

ការគ្រប់គ្រងបែបបន្សាំ (Adaptive Management)៖ លទ្ធផលនៃការតាមដាន និងការវាយតម្លៃ នឹងត្រូវបានបកប្រែទៅជាផែនការគ្រប់គ្រងដែលអាចអនុវត្តបាន ដើម្បីធានានូវភាពធន់រយៈពេលវែងសម្រាប់ដីរៈចម្រុះសមុទ្រ។

VI. ក្របខ័ណ្ឌយុទ្ធសាស្ត្រកៀរគរមូលនិធិ

៦.១ គោលដៅ និងគោលបំណងនៃការកៀរគរមូលនិធិ

ដើម្បីជានាបាននូវមូលដ្ឋានហិរញ្ញប្បទានចម្រុះ និងប្រកបដោយនិរន្តរភាពចំនួនយ៉ាងតិច "**មួយលានដុល្លារសហរដ្ឋអាមេរិច**" ក្នុងរយៈពេលប្រាំឆ្នាំ ដើម្បីគាំទ្រដល់ការការពារ ការស្តារឡើងវិញ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសមុទ្ររបស់កម្ពុជា ព្រមទាំងជានានូវការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។ គោលដៅចម្បង គឺដើម្បីជានានូវនិរន្តរភាពហិរញ្ញវត្ថុរបស់អង្គការ MRPO ក្នុងការអនុវត្តកម្មវិធីប្រចាំឆ្នាំ ២០២៦-២០៣០ របស់ខ្លួន។

គោលបំណងទី ១៖ ជានានូវភាពច្បាស់លាស់នៃហិរញ្ញប្បទានសម្រាប់កម្មវិធីអភិរក្សសមុទ្រស្មូល។

គោលបំណងទី ២៖ ជានានូវការកំណត់គោលដៅម្ចាស់ជំនួយប្រកបដោយប្រសិទ្ធភាព ទាំងក្នុងវិស័យទ្វេភាគី ពហុភាគី និងវិស័យឯកជន។

គោលបំណងទី ៣៖ បង្កើតអាទិភាពនៃការកៀរគរមូលនិធិដែលបំពេញបន្ថែមដល់យុទ្ធសាស្ត្រសមុទ្រថ្នាក់ជាតិ និងអន្តរជាតិ។

៦.២ **ការវិភាគ** SWOT **លើសមត្ថភាពកៀរគរមូលនិធិ**

ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់អង្គការ MRPO គឺជាសំខាន់សម្រាប់ការរៀបចំគោលដៅកៀរគរមូលនិធិឱ្យបានសមស្រប។

ចំណុចខ្លាំង (Strengths)៖ មានគោលបំណងយុទ្ធសាស្ត្រ ៥ ឆ្នាំច្បាស់លាស់ ក្រុមប្រឹក្សាភិបាលដែលមានបទពិសោធន៍ខ្ពស់ ការផ្តោតជាពិសេសលើប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងសេដ្ឋកិច្ចខៀវ។

ចំណុចខ្សោយ (Weaknesses)៖ ស្ថានភាពជាអង្គការដែលទើបបង្កើតថ្មី បុគ្គលិកពេញម៉ោងនៅមានកម្រិត ការពឹងផ្អែកដំបូងលើបណ្តាញដៃគូ។

ឱកាស (Opportunities)៖ ការផ្តោតលើវិទ្យាសាស្ត្រថ្នាក់ជាតិ ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ លំហូរហិរញ្ញប្បទានដែលកំពុងលេចឡើងពី "កាបូនខៀវ" និង "សេដ្ឋកិច្ចខៀវ"។

ការគំរាមកំហែង (Threats)៖ ការប្រកួតប្រជែងខ្ពស់លើការទទួលបានជំនួយឥតសំណង កេរ្តិ៍ឈ្មោះដំបូង ឬទំនុកចិត្តម្ចាស់ជំនួយនៅមានកម្រិត ដោយសារអាយុកាលរបស់អង្គការ។

៦.១ សសរស្តម្ភយុទ្ធសាស្ត្រកៀរគរមូលនិធិ

អង្គការ MRPO នឹងប្រើប្រាស់សសរស្តម្ភចំនួនបួន ដើម្បីធានាបាននូវមូលដ្ឋានហិរញ្ញប្បទានចម្រុះ៖

សសរស្តម្ភ ក៖ ជំនួយឥតសំណងពីស្ថាប័ន និងភាពជាដៃគូបច្ចេកទេស

- **គោលដៅ៖** មូលនិធិបរិស្ថានសកល (GEF) មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (CEPF) មូលនិធិបន្សុំអាកាសធាតុ(Adaptation Fun) សហភាពអឺរ៉ុប (EU) អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ (FAO) អង្គការកម្មវិធីអភិវឌ្ឍន៍នៃសហប្រជាជាតិ (UNDP) និងដៃគូបច្ចេកទេសដូចជា អង្គការអភិរក្សអន្តរជាតិ(CI) អង្គការសត្វព្រៃនិងរុក្ខជាតិ (Fauna & Flora) អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) និង អង្គការ ThinkAqua។
- **សកម្មភាព៖** រួមគ្នាបង្កើតសំណើគម្រោងសម្រាប់ការគ្រប់គ្រងតំបន់ការពារសមុទ្រ (MPA) និងការស្តារទីជម្រកសមុទ្រឡើងវិញ ដែលស្របតាមក្របខ័ណ្ឌជីវៈចម្រុះសកល (30x30)។

សសរស្តម្ភ ខ៖ សេដ្ឋកិច្ចខៀវ និងការចូលរួមជាមួយវិស័យឯកជន

- **គោលដៅ៖** ប្រតិបត្តិករទេសចរណ៍ (មុជទឹក/snorkeling) និងអ្នកអភិវឌ្ឍន៍តំបន់ឆ្នេរ។
- **សកម្មភាព៖** អនុវត្តគំរូ "ការទូទាត់សម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី" (PES) និងចាប់ផ្តើមកម្មវិធី "កាបូនខៀវរបស់សាជីវកម្ម" សម្រាប់ការវិនិយោគលើព្រៃកោងកាង និងស្មៅសមុទ្រ។

សសរស្តម្ភ គ៖ ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព និងនវានុវត្តន៍

- **គោលដៅ៖** ទីផ្សារកាបូនសកល និងអ្នកវិនិយោគដែលមានឥទ្ធិពល (impact investors)។
- **សកម្មភាព៖** រៀបចំការសិក្សាលទ្ធភាពនៃឥណទានកាបូនខៀវ និងបង្កើតមូលនិធិបរធនបាលកិច្ចអភិរក្សសហគមន៍ សម្រាប់គម្រោងជីវភាពរស់នៅដែលមានលក្ខណៈបរិយាបន្ន GEDSI។

៦.២ មូលដ្ឋានទិន្នន័យម្ចាស់ជំនួយ និងយុទ្ធសាស្ត្រភាពជាដៃគូ

ផ្អែកលើយុទ្ធសាស្ត្រកម្មវិធីរយៈពេលប្រាំឆ្នាំរបស់យើង អង្គការ MRPO នឹងរៀបចំសំណើគម្រោងដោយបុរេសកម្ម ដើម្បីដាក់ជូនម្ចាស់ជំនួយចម្រុះ។ ដោយសារ MRPO គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលទើបបង្កើតឡើងថ្មី យើងទទួលស្គាល់ថាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការកៀរគរមូលនិធិប្រកបដោយជោគជ័យ គឺការកសាងភាពជាដៃគូបច្ចេកទេសដ៏រឹងមាំជាមួយអង្គការមិនមែនរដ្ឋាភិបាលអភិរក្សថ្នាក់ជាតិ និងអន្តរជាតិ។ ភាពជាដៃគូទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើនគុណភាពនៃសំណើគម្រោងរបស់យើង និងបង្កើនឱកាសក្នុងការទទួលបានហិរញ្ញប្បទានដ៏សំខាន់។

៦.៣ ភាពជាដៃគូយុទ្ធសាស្ត្រ និងបណ្តាញ

សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល (NGO Alliances)៖ MRPO នឹងស្វែងរកភាពជាដៃគូយ៉ាងសកម្មជាមួយអង្គការអភិរក្សដែលមានស្រាប់ ដើម្បីរួមគ្នាបង្កើតគម្រោងដែលដោះស្រាយបញ្ហាសមុទ្រដ៏ស្មុគស្មាញ។

សមាជិកភាពថ្នាក់ជាតិ និងអន្តរជាតិ (National and International Memberships)៖ ដើម្បីធានាថា យើងស្ថិតនៅជួរមុខនៃកិច្ចសន្ទនាអភិវឌ្ឍន៍ និងការអភិរក្សថ្នាក់ជាតិ និងអន្តរជាតិ MRPO នឹងស្វែងរកសមាជិកភាពក្នុងបណ្តាញសំខាន់ៗ ដូចជាបណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ។

សហថាមពលបច្ចេកទេស (Technical Synergy)៖ យើងនឹងប្រើប្រាស់ភាពជាដៃគូបច្ចេកទេសជាពិសេសដើម្បីបង្កើនភាពមុឺងម៉ាត់ផ្នែកវិទ្យាសាស្ត្រនៃពាក្យស្នើសុំជំនួយឥតសំណងរបស់យើង។

ការគ្រប់គ្រងមូលដ្ឋានទិន្នន័យម្ចាស់ជំនួយ MRPO នឹងរក្សាមូលដ្ឋានទិន្នន័យម្ចាស់ជំនួយដែលមានលក្ខណៈរស់រវើក (ធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ) ដើម្បីកំណត់អត្តសញ្ញាណអ្នកគាំទ្រដែលមានសក្តានុពលប្រកបដោយប្រសិទ្ធភាព។ មូលដ្ឋានទិន្នន័យនេះនឹងត្រូវបានប្រើដើម្បី តាមដានឱកាសជាក់លាក់នានា។

៦.៤ ផែនទីបង្ហាញផ្លូវនៃការអនុវត្ត និងកាលវិភាគ

អង្គការ MRPO នឹងធ្វើវិឌ្ឍន៍ខ្លួនពីការពឹងផ្អែកលើម្ចាស់ជំនួយ ទៅជាការមាននិរន្តរភាពផ្អែកលើទីផ្សារនៅរយៈពេលប្រាំឆ្នាំក្រោយ៖

ប្រភេទហិរញ្ញប្បទាន	២០២៦	២០២៧	២០២៨	២០២៩	២០៣០
ជំនួយឥតសំណង (Grants)	√√√	√√√	√√√	√√√	√√√
សេវាកម្ម/ការប្រឹក្សាយោបល់ (Service/Consultancy)	√√√	√√√	√√√	√√√	√√√
ការលក់ទំនិញ (Merchandising)	√√	√√	√√	√√	√√
ព្រឹត្តិការណ៍កៀរគរមូលនិធិ (Fundraising Events)	√	√	√√	√√	√√
សមាជិកភាព (Membership)	√	√	√	√√	√√

ចំណាំ: √ អាទិភាពទាប √√ អាទិភាពមធ្យម √√√ អាទិភាពខ្ពស់

៦.៥ តួនាទីក្នុងការកៀរគរមូលនិធិ និងអភិបាលកិច្ច

អង្គការ MRPO នឹងរក្សានូវការបែងចែកការងារឱ្យបានច្បាស់លាស់ ដើម្បីធានានូវប្រសិទ្ធភាព និងតម្លាភាព៖

គណៈកម្មាធិការប្រតិបត្តិ (Executive Committee)៖ អង្គភាពនេះនឹងដើរតួនាទីឈានមុខគេក្នុងកិច្ចការប្រចាំថ្ងៃនៃការបង្កើតសំណើគម្រោង ការស្រាវជ្រាវបច្ចេកទេស និងការរាយការណ៍ជូនម្ចាស់ជំនួយ។ គណៈកម្មាធិការប្រតិបត្តិ ដែលដឹកនាំដោយនាយកប្រតិបត្តិ នឹងជួបប្រជុំគ្នាជារៀងរាល់ខែដើម្បីតាមដានវឌ្ឍនភាព។ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ នឹងត្រូវធ្វើឡើងនៅចុងឆ្នាំ ២០២៨។

ក្រុមប្រឹក្សាភិបាល (Governing Board)៖ ក្រុមប្រឹក្សាភិបាលនឹងដើរតួជាអង្គភាពយុទ្ធសាស្ត្រដែលមិនមានលក្ខណៈប្រតិបត្តិ។ ពួកគាត់នឹងផ្តល់ការគាំទ្រដ៏សំខាន់តាមរយៈការកសាងទំនាក់ទំនងកម្រិតខ្ពស់ជាមួយម្ចាស់ជំនួយដែលមានសក្តានុពល ការផ្តល់យោបល់លើមូលដ្ឋានទិន្នន័យម្ចាស់ជំនួយ និងការធានាថាសកម្មភាពកៀរគរមូលនិធិទាំងអស់ប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃសុចរិតភាព និងតម្លាភាព។